## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តសៀមរាប

សំណុំរឿងព្រហ្មទណ្ឌលេខ ៣៨៥
ចុះថ្ងៃទី១៥ ខែមេសា ឆ្នាំ២០២១
សំណុំរឿងជំនុំជម្រះលេខ ៣៩៤
ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២១
សាលក្រមព្រហ្មទណ្ឌលេខ ៤៧"ឃ"/៦១៨
ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២១

## តា ង នា ម ប្រ ជា រា ស្ត្រ ខ្មែ រ
## សាលាដំបូងខេត្តសៀមរាប

បើកសវនាការជាសាធារណៈនៅសាលាដំបូងខេត្តសៀមរាបនាសាលសវនាការលេខ០២។

កាលបរិច្ឆេទបើកសវនាការនៅថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២១ វេលាម៉ោង ២ និង៣០នាទីរសៀល ។

កាលបរិច្ឆេទប្រកាសសាលក្រមនៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២១ វេលាម៉ោង ២ និង៣០ នាទីរសៀល។

### ក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

លោក ក្រុមប្រឹក្សាជំនុំជម្រះ

លោកស្រី ក្រុមប្រឹក្សាជំនុំជម្រះ

### តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តសៀមរាប

### ក្រឡាបញ្ជីសវនាការ

លោកស្រី [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តសៀមរាប

លោកស្រី [redacted] មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] វ៉ាន់ហាង ។

លោក [redacted] មេធាវីការពារសិទ្ធិឲ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ម៉េង ។

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៣៨៥ ចុះថ្ងៃទី១៥ ខែមេសា ឆ្នាំ២០២១ របស់សាលាដំបូងខេត្តសៀមរាប ដែលមានជនជាប់ចោទឈ្មោះ [redacted] វ៉ាន់ហាង ហៅ [redacted] យ៉ាំងហ៊ាង ភេទប្រុស អាយុ ១៥ឆ្នាំ(កើតឆ្នាំ២០០៦) ជនជាតិវៀតណាម មុខរបរ កម្មករ ទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តសៀមរាប ទីលំនៅបច្ចុប្បន្ននៅ [redacted] ខេត្តសៀមរាប កម្រិតវប្បធម៌ថ្នាក់ទី០១ នៅលីវ ឪពុកឈ្មោះ [redacted] យ៉ាំងសួរ(រ) ម្តាយឈ្មោះ [redacted] ធីធីង(ស) ជាអនីតិជន ទោសពីមុនគ្មាន។

ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ២៥៧ ឃខ/គ ចុះថ្ងៃទី១៥ ខែមេសា ឆ្នាំ២០២១

ជាប់ចោទពីបទ៖ ឃាតកម្ម ប្រព្រឹត្តនៅភូមិមាត់ខ្លា ឃុំអន្លង់សំណរ ស្រុកជីក្រែង ខេត្តសៀមរាប កាលពីថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌ ។

ដើមបណ្តឹងរដ្ឋប្បវេណី៖ ឈ្មោះ [redacted] ម៉េង ភេទប្រុស អាយុ៥៥ឆ្នាំ មានទីលំនៅបច្ចុប្បន្នភូមិមាត់ខ្លា ឃុំអន្លង់សំណរ ស្រុកជីក្រែង ខេត្តសៀមរាប ត្រូវជាឪពុកបង្កើតសពឈ្មោះ [redacted] មួយ ឬ [redacted] មួយ ។

- បានឃើញ របាយការណ៍សំយោគលេខ ១១៣/២០២១ ចុះថ្ងៃទី១៥ ខែមេសា ឆ្នាំ២០២១ របស់មន្ត្រីនគរបាលយុត្តិធម៌ ។

- បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ៣៥១ ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២១ របស់អយ្យការអមសាលាដំបូងខេត្តសៀមរាប ។

- បានឃើញ ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ២២៨៨ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តសៀមរាប ។

- បានឃើញ ដីកាចាត់តាំងក្រុមប្រឹក្សាជំនុំជម្រះលេខ ៨៣៥ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២១ របស់ប្រធានសាលាដំបូងខេត្តសៀមរាប ។

## ឯអង្គហេតុកើតមានដូចតទៅ

កាលពីថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២១ វេលាម៉ោង ៨ និង ០០នាទីព្រឹក ឈ្មោះ [redacted] វ៉ាន់ហាង ភេទប្រុស អាយុ១៥ឆ្នាំ និងឈ្មោះ [redacted] មួយ ឬ [redacted] មួយ ភេទស្រី អាយុ ១៣ឆ្នាំ បានចេញកាណូតទៅលក់កាហ្វេ និងភេសជ្ជៈផ្សេងៗនៅតាមផ្ទះ ដោយមុនពេលចេញឈ្មោះ [redacted] វ៉ាន់ហាង និងឈ្មោះ [redacted] មួយ ឬ [redacted] មួយ បានឈ្លោះប្រកែកគ្នា។ លុះមកដល់ម៉ោង ១៤ និង០០នាទី [redacted] វ៉ាន់ហាង និងឈ្មោះ [redacted] មួយ ឬ [redacted] មួយ បានត្រឡប់មកវិញមកដល់ចំណុចផ្លូវព្រួល ស្ថិតនៅភូមិមាត់ខ្លា ឃុំអន្លង់សំណរ ស្រុកជីក្រែង ខេត្តសៀមរាប ពួកគេទាំងពីរនាក់បានឈ្លោះគ្នាម្តងទៀតដោយឈ្មោះ [redacted] មួយ បានជេរ និងបានយកកាំបិតកាប់មកលើឈ្មោះ [redacted] វ៉ាន់ហាង ធ្វើឲ្យខឹងទ្រាំមិនបានក៏បានស្ទុះយកញញួរវាយទៅលើឈ្មោះ [redacted] មួយ ចំក្បាល បណ្តាលឲ្យឈ្មោះ [redacted] មួយ ប្រកាច់ធ្លាក់ចូលទឹកស្លាប់តែម្តង ។

## នាពេលសវនាការ

- តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] វ៉ាន់ហាង ហៅ [redacted] យ៉ាំងហ៊ាង បានឆ្លើយថា៖ កាលពីថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២១ វេលាម៉ោង ៨ និង០០នាទីព្រឹក ខ្លួន និងឈ្មោះ [redacted] មួយ ឬ [redacted] មួយ ភេទស្រី អាយុ១៣ឆ្នាំ បានចេញទៅលក់កាហ្វេ និងភេសជ្ជៈផ្សេងៗនៅតាមភូមិ និងតាមផ្ទះ ដោយកាណូត ប៉ុន្តែមុនពេលចេញទៅលក់ ខ្លួននិងឈ្មោះ [redacted] មួយ បានឈ្លោះប្រកែកគ្នា ដោយសារតែខ្លួនប្រាប់ថា កុំដាក់ឥវ៉ាន់លើទូកច្រើនពេកខ្លួនមើលផ្លូវខាងមុខមិនឃើញទេ ព្រោះខ្លួនជាអ្នកបើកកាណូត ។ ក្រោយពីចេញទៅលក់ដូរហូតដល់ម៉ោងប្រហែល ១៤ និង០០នាទី ខ្លួន និងឈ្មោះ [redacted] មួយ បានត្រឡប់មកវិញ មកដល់ចំណុចផ្លូវព្រួល ខាងត្បូងភូមិមាត់ខ្លា ឃុំអន្លង់សំណរ ស្រុកជីក្រែង ខេត្តសៀមរាប ក៏បានឈ្លោះគ្នាម្តងទៀត ពេលនោះឈ្មោះ [redacted] មួយ បានជេរម្តាយខ្លួនៗប្រាប់ទៅវិញថាកុំជេរម្តាយខ្លួន គាត់អត់ដឹងអ្វីទេ ភ្លាមនោះឈ្មោះ [redacted] មួយ បានយកកាំបិតកាប់ទឹកកកគប់មកលើក្បាលរបស់ខ្លួនបណ្តាលឲ្យមុតនិងរបួស ថែមទាំងយកច្រវ៉ាអុំទូកវាយស្បើខ្លួនទៀត ដោយសារខ្លួនខឹងនឹងការជេរម្តាយរបស់ខ្លួន និងការគប់កាំបិតត្រូវខ្លួន វាយត្រូវខ្លួនៗទ្រាំមិនបានក៏ស្ទុះយកញញួរដែលនៅលើកាណូតវាយទៅលើឈ្មោះ [redacted] មួយ ចំក្បាលមួយញញួរ បណ្តាលឲ្យប្រកាច់ធ្លាក់ទឹកភ្លាមតែម្តង។

បន្ទាប់មកខ្លួនបានយកញញួរទៅវាយកាណូតបែកបន្តិច ដើម្បីបំភាន់អ្នកដទៃថា ខ្លួនត្រូវចោរប្លន់ ហើយបានទូរស័ព្ទប្រាប់ឪពុករបស់ជនរងគ្រោះថា កូនស្រីគាត់ត្រូវបានគេបើកកាណូតបុកប្លន់ស្លាប់ហើយ។ ពេលឈ្មោះ [redacted] មួយ ធ្លាក់ទឹកខ្លួនក៏បានជួយចាប់នាងតែជួយមិនបានខ្លួនបានស្រែកហៅឲ្យគេជួយដែរ តែនៅកន្លែងកើតហេតុនោះស្ងាត់គ្មានមនុស្សទេ ។

- តាមចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ម៉េង បានឆ្លើយថា៖ កន្លងមកខ្លួនបានជួលកម្មករម្នាក់ឈ្មោះ [redacted] វ៉ាន់ហាង ហៅ [redacted] យ៉ាំងហ៊ាង ភេទប្រុស អាយុ១៥ឆ្នាំ ដោយឲ្យប្រាក់ខែក្នុង ០១ខែ ៥០ម៉ឺនរៀល ដើម្បីបើកកាណូតឲ្យកូនស្រីខ្លួនលក់ឥវ៉ាន់ជារៀងរាល់ថ្ងៃ មិនដែលមានបញ្ហាអ្វីទេ ប៉ុន្តែពួកគេធ្លាប់ឈ្លោះគ្នាជាញឹកញាប់ដែរ ហេតុថ្មីៗមុនពេលកើតហេតុ ពួកវាបានឈ្លោះគ្នាទៀត ។ នៅថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២១ វេលាម៉ោង១៣និង០០នាទី ឈ្មោះ [redacted] វ៉ាន់ហាង បានទូរស័ព្ទមកប្រាប់ខ្លួនថា មានចោរប្លន់បើកទូកបុកទូកឥវ៉ាន់ និងបុកត្រូវឈ្មោះ [redacted] មួយ អូសធ្លាក់ពីលើទូកចូលកំប្លោកលិចក្នុងទឹកស្លាប់ហើយ ពេលខ្លួនបានដឹងភ្លាម ខ្លួនបានហៅអ្នកជិតខាងទៅមើលកន្លែងកើតហេតុ ពេលទៅដល់ឃើញតែឈ្មោះ [redacted] វ៉ាន់ហាង នៅលើទូក ចំណែកកូនស្រីរបស់ខ្លួនឈ្មោះ [redacted] មួយ មិនឃើញទេ ហើយបាននាំគ្នាចុះរាវក្នុងទឹករកសពកូនរបស់ខ្លួន ក៏នាំយកមកផ្ទះ ។ ក្រោយមកសមត្ថកិច្ចបានចុះស្រាវជ្រាវ និងសាកសួរដំណើររឿងករណីការស្លាប់កូនស្រីរបស់ខ្លួន ពេលនោះឈ្មោះ [redacted] វ៉ាន់ហាង បានឆ្លើយថាចោរប្លន់មានគ្នា០៣នាក់ ប៉ុន្តែមិនបានបាត់បង់លុយកាក់ទូរស័ព្ទ និងឥវ៉ាន់ទេទើបខ្លួនមានការសង្ស័យលើឈ្មោះ [redacted] វ៉ាន់ហាង ។

- អ្នកទទួលខុសត្រូវរដ្ឋប្បវេណីឈ្មោះ [redacted] យ៉ាំងសួរ បានឆ្លើយថា៖ ខ្លួនជាឪពុករបស់ឈ្មោះ [redacted] វ៉ាន់ហាង។ កាលពីថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២១ វេលាម៉ោង ៣រសៀល ឪពុករបស់ជនរងគ្រោះបានហៅខ្លួនឲ្យជួយដោយប្រាប់ថាមានចោរប្លន់កូន នៅម្តុំផ្លូវមាត់ព្រួល ស្ថិតនៅភូមិមាត់ខ្លា ឃុំអន្លង់សំណរ ស្រុកជីក្រែង ខេត្តសៀមរាប ។ ពេលទៅជួយមានគ្នាច្រើននាក់ចេញទៅជាមួយឪពុករបស់ជនរងគ្រោះ ពេលទៅដល់ឃើញកូនប្រុសរបស់ខ្លួនបាននៅលើកាណូត ហើយពួកខ្លួននាំគ្នាស្រវារកក្នុងទឹកក៏ឃើញឈ្មោះ [redacted] មួយ នៅក្នុងទឹកឆ្ងាយពីកាណូតប្រហែល ៣០ម៉ែត្រ។ ពេលស្រង់ឈ្មោះ [redacted] មួយ មកឃើញមានស្នាមរបួសនៅលើក្បាលរបស់នាង។ កូនប្រុសខ្លួនកើតនៅថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០០៦ (ឆ្នាំច)។ ខ្លួនបានជួយប្រាក់ធ្វើបុណ្យដល់គ្រួសារជនរងគ្រោះបាន ១៥,០០០,០០០ (ដប់ប្រាំលានដុង) រួចហើយ ខ្លួនពុំមានលទ្ធភាពសងសំណងដល់ដើមបណ្ដឹងទេ ព្រោះគ្រួសារខ្លួនមានជីវភាពក្រីក្រលំបាកពុំមានប្រាក់ច្រើនដើម្បីសងសំណងឡើយ ។

- តាមអំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] រៀម បានឆ្លើយថា៖ នៅថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២១ ម៉ោង ៧ព្រឹក ឈ្មោះ [redacted] មួយ និងឈ្មោះ [redacted] វ៉ាន់ហ៊ាង បានបើកកាណូតចូលមកផ្ទះរបស់ខ្លួនដើម្បីលក់ឥវ៉ាន់ ហើយខ្លួនបានទិញកូកា១កែវធំ និងកូនស្រីខ្លួនទិញអង្ករ ១គីឡូក្រាម ពេលនោះស្រាប់តែមេឃធ្លាក់ភ្លៀង ខ្លួននិងកូនបានឃាត់ពួកគេថាកុំទាន់ចេញទៅព្រោះមេឃកំពុងភ្លៀង តែពួកគេមិនព្រមនៅទេក៏បើកកាណូតចេញទៅបាត់រហូតដល់ម៉ោង ១៤ និង០០នាទី ថ្ងៃដដែល ទើបដឹងថាឈ្មោះ [redacted] មួយ បានស្លាប់បាត់ទៅហើយ ។

- មេធាវីការពារសិទ្ធិឲ្យដើមបណ្ដឹងរដ្ឋប្បវេណីលោក [redacted] បានធ្វើសេចក្តីសន្និដ្ឋានថា៖ ក្រោយពីបានដេញដោលនាពេលសវនាការរួចហើយ ឃើញថា ជនជាប់ចោទបានឆ្លើយសារភាពថាខ្លួនពិតជាបានយក



Scanned with CamScanner

ញញួរវាយទៅលើជនរងគ្រោះបណ្ដាលឲ្យបាត់បង់ជីវិត ហើយជនជាប់ចោទបង្វែររឿងថាចោរប្លន់ទៅវិញ ។ អំពើប្រព្រឹត្តរបស់ជនជាប់ចោទបង្កឲ្យព្យសនកម្មដល់សង្គម និងធ្វើឲ្យគ្រួសារមានការឈឺចាប់ខ្លាំង។ សំណូមពរសុំតុលាការសម្រេចផ្ដន្ទាទោសជនជាបចោទតាមច្បាប់ និងពិចារណាសម្រេចអំពីសំណងរដ្ឋប្បវេណីតាមការទាមទាររបស់ដើមបណ្ដឹងរដ្ឋប្បវេណីដោយអនុគ្រោះ ។

- តំណាងអយ្យការបានធ្វើសេចក្ដីសន្និដ្ឋានថា៖ ក្រោយពីបានធ្វើការពិភាក្សាដេញដោលនាពេលសវនាការរួចមក ជនជាប់ចោទបានឆ្លើយសារភាពទទួលស្គាល់នូវទង្វើប្រព្រឹត្តរបស់ខ្លួន ដូច្នេះតំណាងអយ្យការសុំរក្សាបទចោទតាមដីកាសន្និដ្ឋានស្ថាពរទុកជាបានការដដែល និងស្នើសុំតុលាការសម្រេចផ្ដន្ទាទោសជនជាប់ចោទតាមច្បាប់ ។

- មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទលោកស្រី [redacted] បានធ្វើសេចក្ដីសន្និដ្ឋានថា៖ ក្រោយពីឆ្លងការដេញដោលរួចមក ជនជាប់ចោទនិងជនរងគ្រោះបានឈ្លោះប្រកែកពាក្យសម្ដី និងបានប្រតាយប្រតប់គ្នា ហើយជនរងគ្រោះបានយកកាំបិតវាយត្រូវក្បាលកូនក្ដីខ្លួនបណ្ដាលឲ្យចេញឈាម ហើយកូនក្ដីខ្លួនខឹងក៏បានឃើញញញួរនៅជិតវាយទៅលើជនរងគ្រោះវិញបណ្ដាលឲ្យជនរងគ្រោះធ្លាក់ទឹក ហើយកូនក្ដីខ្លួនបានស្រែកឲ្យគេជួយ ។ កូនក្ដីខ្លួនបានឆ្លើយសារភាពទទួលស្គាល់នូវកំហុសរបស់ខ្លួន ម្យ៉ាងទៀតកូនក្ដីខ្លួនជាអនីតិជនមានអាយុ១៥ឆ្នាំ គ្មានចេតនាវាយសម្លាប់ជនរងគ្រោះបណ្ដាលឲ្យស្លាប់ឡើយ តែពេលនោះខ្វះការពិចារណាដោយឃើញញញួរនៅលើទូកក៏ទាញមកវាយតបវិញប៉ុណ្ណោះ ។ បើពិនិត្យទៅលើវត្ថុចាប់យកញញួរនោះមិនមែនជាមធ្យោបាយប្រព្រឹត្តបទល្មើសឡើយព្រោះញញួរនៅលើទូកស្រាប់ ហើយកូនក្ដីខ្លួនមិនមានចេតនាទុកញញួរដើម្បីប្រព្រឹត្តបទល្មើសឡើយ ដូច្នេះស្នើសុំតុលាការពិចារណាប្ដូរបទចោទពីបទ៖ ឃាតកម្ម តាមមាត្រា១៩៩ នៃក្រមព្រហ្មទណ្ឌ មកបទ៖មនុស្សឃាតដោយអចេតនា តាមមាត្រា២០៧ នៃក្រមព្រហ្មទណ្ឌ ស្នើសុំក្រុមប្រឹក្សាជំនុំជម្រះពិចារណាផ្ដល់ស្ថានសម្រាលទោសឲ្យកូនក្ដីខ្លួនព្រោះកូនក្ដីខ្លួនជាអនីតិជន ។

- សំណូពររបស់ដើមបណ្ដឹងរដ្ឋប្បវេណី៖ ខ្លួនប្ដឹងសុំទាមទារសំណងជម្ងឺចិត្ត ចំនួន ៨០,០០០,០០០ (ប៉ែតសិបលាន)រៀល និងស្នើសុំឲ្យផ្ដន្ទាទោសជនជាប់ចោទតាមច្បាប់ ។

- សំណូមពរសម្ដីចុងក្រោយរបស់ជនជាប់ចោទ៖ ស្នើសុំតុលាការបន្ធូរបន្ថយទោសផង ។

- ក្រោយពីបានស្ដាប់ចម្លើយរបស់ជនជាប់ចោទ
- ក្រោយពីបានស្ដាប់ចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី
- ក្រោយពីបានស្ដាប់ចម្លើយរបស់អ្នកទទួលខុសត្រូវរដ្ឋប្បវេណី
- ក្រោយពីបានស្ដាប់អំណានចម្លើយរបស់សាក្សីបំភ្លឺ
- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនរងគ្រោះ
- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានប្ដឹងសុំរបស់តំណាងអយ្យការ
- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានសុំរបស់មេធាវីការពារឲ្យជនជាប់ចោទ
- ក្រោយពីបានពិនិត្យលើឯកសារភស្ដុតាង និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ



Scanned with CamScanner

# សាលាដំបូងខេត្តសៀមរាប

## យល់ឃើញថា

- កាលពីថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២១ វេលាម៉ោង ៨ និង ០០នាទីព្រឹក ឈ្មោះ [redacted] វ៉ាន់ហាង ភេទប្រុស អាយុ១៥ឆ្នាំ និងឈ្មោះ [redacted] មួយ ឬ [redacted] មួយ ភេទស្រី អាយុ ១៣ឆ្នាំ បានចេញកាណូតទៅលក់កាហ្វេ និងភេសជ្ជៈផ្សេងៗនៅតាមផ្ទះ ដោយមុនពេលចេញឈ្មោះ [redacted] វ៉ាន់ហាង និងឈ្មោះ [redacted] មួយ ឬ [redacted] មួយ បានឈ្លោះប្រកែកគ្នា។ លុះមកដល់ម៉ោង ១៤ និង០០នាទី [redacted] វ៉ាន់ហាង និងឈ្មោះ [redacted] មួយ ឬ [redacted] មួយ បានត្រឡប់មកវិញមកដល់ចំណុចផ្លូវព្រួល ស្ថិតនៅភូមិមាត់ខ្លា ឃុំអន្លង់សំណរ ស្រុកជីក្រែង ខេត្តសៀមរាប ពួកគេទាំងពីរនាក់បានឈ្លោះគ្នាម្តងទៀតដោយឈ្មោះ [redacted] មួយ បានជេរនិងបានយកកាំបិតកាប់មកលើឈ្មោះ [redacted] វ៉ាន់ហាង ធ្វើឲ្យខឹងទ្រាំមិនបានក៏បានស្ទុះយកញញួរវាយទៅលើឈ្មោះ [redacted] មួយ ចំក្បាលបណ្តាលឲ្យប្រកាច់ធ្លាក់ចូលទឹកស្លាប់តែម្តង ។

- ជនជាប់ចោទត្រូវបានចៅក្រមស៊ើបសួរសម្រេចបញ្ជូនសំណុំរឿងមកជំនុំជម្រះតាមដីកាសម្រេច លេខ៖ ២២៨៨ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២១ ពីបទ៖ ឃាតកម្ម ប្រព្រឹត្តនៅភូមិមាត់ខ្លា ឃុំអន្លង់សំណរ ស្រុកជីក្រែង ខេត្តសៀមរាប កាលពីថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២១ តាមបញ្ញត្តិមាត្រា១៩៩ នៃក្រមព្រហ្មទណ្ឌ ។

- តាមចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សីបំភ្លឺ និងចម្លើយសារភាពរបស់ជនជាប់ចោទមានភាពស៊ីសង្វាក់គ្នាទៅនឹងអង្គហេតុ និងរបាយការណ៍សំយោគរបស់មន្ត្រីនគរបាលយុត្តិធម៌ ព្រមទាំងឯកសារនានាមាននៅក្នុងសំណុំរឿង ឃើញថាកាលពីថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២១ ពិតជាមានករណី "ឃាតកម្ម" បង្កឡើងដោយឈ្មោះ [redacted] វ៉ាន់ហាង ហៅ [redacted] យ៉ាំងហ៊ាង ភេទប្រុស អាយុ១៥ឆ្នាំ ប្រាកដមែន ។

- សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យដើមបណ្តឹងរដ្ឋប្បវេណី ថា ក្រោយពីបានដេញដោលនាពេលសវនាការរួចហើយ ឃើញថា ជនជាប់ចោទបានឆ្លើយសារភាពថាខ្លួនពិតជាបានយក ញញួរវាយទៅលើជនរងគ្រោះបណ្តាលឲ្យបាត់បង់ជីវិត ហើយជនជាប់ចោទបង្វែររឿងថាចោរប្លន់ទៅវិញ ។ អំពើប្រព្រឹត្តរបស់ជនជាប់ចោទបង្កឲ្យព្យសនកម្មដល់សង្គមនិងធ្វើឲ្យគ្រួសារមានការឈឺចាប់ខ្លាំង។ សំណូមពរសុំតុលាការសម្រេចផ្តន្ទាទោសជនជាបចោទតាមច្បាប់ និងពិចារណាសម្រេចអំពីសំណងរដ្ឋប្បវេណី តាមការទាមទាររបស់ដើមបណ្តឹងរដ្ឋប្បវេណី ។ គប្បីតុលាការសម្រេចតាមច្បាប់ ។

- សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ ថា ក្រោយពីបានធ្វើការពិភាក្សាដេញដោលនាពេលសវនាការរួចមកជនជាប់ចោទបានឆ្លើយសារភាពទទួលស្គាល់នូវទង្វើប្រព្រឹត្តរបស់ខ្លួន ដូច្នេះតំណាងអយ្យការ សុំរក្សាបទចោទតាមដីកាសន្និដ្ឋានស្ថាពរទុកជាបានការដដែល និងស្នើសុំតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ ។ គប្បីតុលាការសម្រេចតាមច្បាប់ ។

- សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ ថា ក្រោយពីឆ្លងការដេញដោលរួចមកជនជាប់ចោទនិងជនរងគ្រោះបានឈ្លោះប្រកែកពាក្យសម្តី និងបានប្រតាយប្រតប់គ្នា ហើយជនរងគ្រោះបានយកកាំបិតវាយត្រូវក្បាលកូនក្តីខ្លួនបណ្តាលឲ្យចេញឈាម ហើយកូនក្តីខ្លួនខឹងក៏បានឃើញញញួរនៅជិតវាយទៅលើជនរងគ្រោះវិញបណ្តាលឲ្យជនរងគ្រោះធ្លាក់ទឹក ហើយកូនក្តីខ្លួនបានស្រែកឲ្យគេជួយ ។ កូនក្តីខ្លួនបានឆ្លើយសារ



Scanned with CamScanner

ភាពទទួលស្គាល់នូវកំហុសរបស់ខ្លួន ម្យ៉ាងទៀតកូនក្តីខ្លួនជាអនីតិជនមានអាយុ១៥ឆ្នាំ គ្មានចេតនាវាយសម្លាប់ជនរងគ្រោះបណ្តាលឲ្យស្លាប់ឡើយ តែពេលនោះខ្វះការពិចារណាដោយឃើញញញួរនៅលើទូកក៏ទាញមកវាយតបវិញប៉ុណ្ណោះ ។ បើពិនិត្យទៅលើវត្ថុចាប់យកញញួរនោះមិនមែនជាមធ្យោបាយប្រព្រឹត្តបទល្មើសឡើយ ព្រោះញញួរនៅលើទូកស្រាប់ ហើយកូនក្តីខ្លួនមិនមានចេតនាទុកញញួរដើម្បីប្រព្រឹត្តបទល្មើសឡើយ ដូច្នេះស្នើសុំតុលាការពិចារណាប្តូរបទចោទពីបទ៖ ឃាតកម្ម តាមមាត្រា១៩៩ នៃក្រមព្រហ្មទណ្ឌ មកបទ៖ មនុស្សឃាតដោយអចេតនា តាមមាត្រា២០៧ នៃក្រមព្រហ្មទណ្ឌ ស្នើសុំក្រុមប្រឹក្សាជំនុំជម្រះពិចារណាផ្តល់ស្ថានសម្រាលទោសឲ្យកូនក្តីខ្លួនដែលជាអនីតិជនផង ។ គប្បីតុលាការពិចារណាសម្រេចតាមច្បាប់ ។

- អំពើប្រព្រឹត្តរបស់ជនជាប់ចោទ ធ្វើឲ្យប៉ះពាល់ដល់អាយុជីវិតអ្នកដទៃ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈជាពិសេសខុសនឹងច្បាប់ព្រហ្មទណ្ឌជាធរមាន ។

- ជនជាប់ចោទជាជនដែលអាចយល់ដឹងគ្រប់គ្រាន់ និងមានស្មារតីរឹងមាំអាចដឹងចំពោះអំពើរបស់ខ្លួនដែលបានប្រព្រឹត្តដូច្នេះអាចទទួលការចោទប្រកាន់បាន ។

- ជនជាប់ចោទឈ្មោះ [redacted] វ៉ាន់ហាង ហៅ [redacted] យ៉ាំងប៊ាង ភេទប្រុស អាយុ១៥ឆ្នាំ ជាអនីតិជនគប្បីតុលាការផ្តល់ស្ថានសម្រាលទោស ស្របតាមមាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌ ។

- មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] វ៉ាន់ហាង ហៅ [redacted] យ៉ាំងប៊ាង ភេទប្រុស អាយុ១៥ឆ្នាំ ពីបទ ឃាតកម្ម ប្រព្រឹត្តនៅភូមិមាត់ខ្លា ឃុំអន្លង់សំណរ ស្រុកជីក្រែង ខេត្តសៀមរាប កាលពីថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌ ។

- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ម៉េង បានទាមទារសំណងជម្ងឺចិត្ត ចំនួន ៨០,០០០,០០០ (ប៉ែតសិបលាន)រៀល។ គប្បីតុលាការពិចារណាតាមស្ថានភាពជាក់ស្តែង ។

- វត្ថុចាប់យករួមមាន៖ ញញួរដងឈើចំនួន ០១ដើម ,មួកចំនួន០១, ខោចំនួន០១ និងអាវចំនួន ០១ គប្បីតុលាការសម្រេចតាមមាត្រា៦២ និងមាត្រា៦៣ នៃក្រមព្រហ្មទណ្ឌ ។

## ហេតុដូច្នេះ សម្រេច

១- ផ្តន្ទាទោសលើឈ្មោះ [redacted] វ៉ាន់ហាង ហៅ ង្វៀង យ៉ាំងប៊ាង ភេទប្រុស អាយុ១៥ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ៥(ប្រាំ)ឆ្នាំ ពីបទ ឃាតកម្ម ប្រព្រឹត្តនៅភូមិមាត់ខ្លា ឃុំអន្លង់សំណរ ស្រុកជីក្រែង ខេត្តសៀមរាប កាលពីថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា១៩៩ និងមាត្រា១៦០ នៃក្រមព្រហ្មទណ្ឌ ។

២- បង្គាប់ឲ្យឈ្មោះ [redacted] យ៉ាំងសួរ ជាអ្នកទទួលខុសត្រូវរដ្ឋប្បវេណី(ឪពុកបង្កើតរបស់ជនជាប់ចោទ) សងសំណងជម្ងឺចិត្តចំនួន៨០,០០០,០០០(ប៉ែតសិបលាន)រៀល ទៅឲ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted] ម៉េង ការទាមទារលើសពីនេះបដិសេធចោល ។

៣- វត្ថុចាប់យករួមមាន៖

ក- ញញួរដងឈើ ចំនួន០១ដើម សម្រេចរឹបអូសជាសម្បត្តិរដ្ឋ ។

ខ- មួកចំនួន០១ ខោចំនួន០១ និងអាវចំនួន០១ សម្រេចរឹបអូសបំផ្លាញចោល ។



Scanned with CamScanner

សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២១ ចំពោះមុខជនជាប់ចោទ និងដើមបណ្ដឹងរដ្ឋប្បវេណី និងប្រកាសជាសាធារណៈ នៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២១ ។

"ទុកសិទ្ធិប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់"

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
| --- | --- | --- | --- |
| ហត្ថលេខា និងត្រា | ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា និងត្រា |

[redacted]

"បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃពុធ ៩រោច ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥

សៀមរាប ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២១

ក្រឡាបញ្ជី

[redacted]

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]